ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០២៦៤...សហវ.ពដ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០០៦

# សេចក្តីជូនដំណឹង

## ស្តីពីការប្រើប្រាស់វិក្កយបត្រសំរាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត)

អនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និង បទប្បញ្ញត្តិស្តីពីអាករលើតម្លៃបន្ថែម (អតប) នៅពេលលក់ទំនិញ ឬសេវា សហគ្រាសដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស (របបពិត) ត្រូវមានកាតព្វកិច្ចចេញវិក្កយបត្រ អតប ឱ្យអតិថិជនដែលជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសដូចគ្នា និងចេញវិក្កយបត្រធម្មតាឱ្យអតិថិជនជាអ្នកជាប់ពន្ធតាមរបបម៉ៅការ ឬអ្នកទិញប្រើប្រាស់ធម្មតា។ ក្នុងរយៈពេលកន្លងមក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យឃើញថា សហគ្រាសមួយចំនួនបានចេញវិក្កយបត្រត្រឹមត្រូវ ដោយឡែកសហគ្រាសមួយចំនួនទៀតមិនបានចេញ ឬបានចេញវិក្កយបត្រមិនត្រឹមត្រូវ។

ដើម្បីពង្រឹងការគ្រប់គ្រងរបបស្វ័យប្រកាស និងដើម្បីធានាការប្រើប្រាស់វិក្កយបត្រឱ្យបានត្រឹមត្រូវក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំឱ្យសហគ្រាសអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ត្រូវចេញវិក្កយបត្រ អតប ដូចមានចែងក្នុងមាត្រា ៧៧ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមានខ្លឹមសារសំខាន់ៗជាអាទិ៍: ឈ្មោះ អាសយដ្ឋាន និងលេខអត្ត-សញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់និងអ្នកទិញ លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញ វិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា តម្លៃសរុបប្រាក់ អតប ។ល។ វិក្កយបត្រត្រូវប្រើប្រាស់តាមលំដាប់លេខរៀងឱ្យបានត្រឹមត្រូវ និងត្រូវរក្សាទុកក្នុងរយៈពេល ១០ ឆ្នាំ។

ការមិនចេញវិក្កយបត្រ ឬបានចេញវិក្កយបត្រមិនត្រឹមត្រូវ ត្រូវចាត់ទុកជាអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារតាមមាត្រា ១២៨ នៃច្បាប់ស្តីពីសារពើពន្ធ និងត្រូវរងទោសទណ្ឌដូចមានចែងក្នុងមាត្រា ១៣៣ និងមាត្រា ១៣៦ នៃច្បាប់ស្តីពីសារពើពន្ធ ក្នុងនោះមានការបិទសហគ្រាសក្នុងរយៈពេល ០៧ ថ្ងៃ ការផាកពិន័យជាប្រាក់រហូតដល់ ១០.០០០.០០០ រៀល ឬជាប់ពន្ធធនាគាររហូតដល់ ០១ ឆ្នាំ ឬទោសទាំងពីរ។

ចាប់ពីថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០៦ តទៅ នាយកដ្ឋានពន្ធដារនឹងធ្វើការពង្រឹងបន្ថែមនូវការចុះអង្កេតត្រួតពិនិត្យដល់ទីកន្លែង ដើម្បីពិនិត្យការប្រើប្រាស់វិក្កយបត្រដូចបានជំរាបជូនខាងលើ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក៏សូមអំពាវនាវផងដែរដល់លោក លោកស្រីជាអ្នកទិញ សូមមេត្តាទាមទារវិក្កយបត្រពីអ្នកលក់នៅរាល់ពេលទិញទំនិញ ឬសេវា។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសង្ឃឹម និងជឿជាក់ថា លោក លោកស្រី ម្ចាស់សហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់យកចិត្តទុកដាក់អនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**<u>ចម្លងជូន</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីជូនជារបាយការណ៍"

- គ្រប់ក្រសួង-ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត-ក្រុង

"ដើម្បីជូនជ្រាប"

- គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "ដើម្បីមុខការ"
- គ្រប់អង្គភាពពន្ធដារខេត្ត-ក្រុង "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798